**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ១ និងមាត្រា ៣ នៃអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីកាត់ដីសរុបទំហំ ២.២៩៧,០៨ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដែលក្នុងនោះទំហំ ២.១៨២,៨២ ហិកតាដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២.៣៣៤ គ្រួសារ និងដីទំហំ ១១៤,២៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ និងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ លើ ៣.៣៩៩ ក្បាលដី ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីកាត់ដីសរុបទំហំ២.២៩៧,០៨ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដែលក្នុងនោះទំហំ ២.១៨២,៨២ ហិកតាដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២.៣៣៤ គ្រួសារ និងដីទំហំ១១៤,២៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ និងផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ លើ ៣.៣៩៩ ក្បាលដី ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែងនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- តាមសំណើលេខ ១៣៨ អបខ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា មួយ..**

កែសម្រួលចំណុចមួយចំនួនដែលមានចែងក្នុងមាត្រា១ និងមាត្រា ៣ នៃអនុក្រឹត្យលេខ ២១៩ អនក្រ.បកចុះថ្ងៃទី០១ខែធ្នូឆ្នាំ២០១២ ស្តីពីកាត់ដីសរុបទំហំ២.២៩៧,០៨ ហិកតាចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ ដែលក្នុងនោះទំហំ២.១៨២,៨២ ហិកតាដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២.៣៣៤ គ្រួសារ និងដីទំហំ១១៤,២៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ និងផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.៣៣៤ គ្រួសារ លើ ៣.៣៩៩ ក្បាលដី ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែងនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដូចខាងក្រោមៈ

**មាត្រា ១** ចំណុច២.១ **ថ្មី៖**

-ផ្ទៃដីសរុបទំហំ ២៣៣,២៣ ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ២២០,១៩ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៣,០៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិ ត្រពាំងគុល ។

**មាត្រា ៣** វាក្យខណ្ឌទី១ **ថ្មី៖**

-ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ២.១០៥ ក្បាលដីក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១.៤៤៩ គ្រួសារ លើ ២.០៩៧ ក្បាលដី និងផ្តល់សិទ្ធជាកម្មសិទ្ធិសាធារណៈ០៤ ក្បាលដី (ដីសាលារៀន០១ក្បាលដី ដីស្នាក់ការភូមិ០១ក្បាលដី ដីសាលាឃុំ០១ក្បាលដី និងប៉ុស្តិ៍រដ្ឋបាលឃុំ០១ក្បាលដី) កម្មសិទ្ធិអវិភាគភូមិចំនួន៣ក្បាលដី (ដីស្រះទឹក) និងអចលនវត្ថុរបស់វត្ត០១ ក្បាលដី ដែលក្នុងនោះ

-ត្រូវបានលុបចោលទាំងស្រុងនូវចំណុចមួយចំនួនក្នុងមាត្រា៣(ចាស់)ដូចខាងក្រោម ៖

- ចំណុច៣.២ នៅក្នុងឃុំត្រាចទង មានចំនួន ០៧ ចំណុច ចាប់ពីត្រៃទី១ ដល់ ត្រៃទី៧ គឺភូមិត្រពាំងគុល ភូមិបឹងវ៉ា ភូមិក្រាំងគ្រប់ ភូមិទួលខ្លុង ភូមិក្រសាំងផ្អែម ភូមិត្រពាំងលើក និងភូមិអណ្តូងច្រុះ
- ចំណុច៣.៣ នៅក្នុងឃុំមានជ័យ មានចំនួន ០២ ចំណុចត្រៃទី១ និងត្រៃទី២ គឺភូមិស្តុកស្អាត និងភូមិស្តុក ។

**មាត្រា ៤ ថ្មី..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី សរុបចំនួន ១.២៩៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ១.២៩៤ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៨៨៦ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិសាធារណៈចំនួន០៤ ក្បាលដី(ដីទួលអ្នកតា០២ក្បាលដី និងត្រពាំងទឹក ០២ ក្បាលដី) នៅខេត្តកំពង់ស្ពឺ ស្រុកឧដុង្គ ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

ក. ឃុំត្រាចទងមាន ០៧ភូមិ រួមមាន ៖

- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន៣៧៥ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២៦៦ គ្រួសារ និងផ្ដល់សិទ្ធិជាកម្មសិទ្ធិសាធារណៈចំនួន០៩ ក្បាលដី (ត្រពាំងទឹក) នៅភូមិត្រពាំងក្ដុល
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ១១៣ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៧០ គ្រួសារ និងផ្ដល់សិទ្ធិជាកម្មសិទ្ធិសាធារណៈចំនួន០១ ក្បាលដី នៅភូមិបឹងវ៉ា
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ២២១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១០១ គ្រួសារ នៅភូមិក្រាំងគ្រប់
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ០៣ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ០២ គ្រួសារ នៅភូមិទួលខ្លុង
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ៨៣ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៧០ គ្រួសារ និងផ្ដល់សិទ្ធិជាកម្មសិទ្ធិសាធារណៈចំនួន ០១ ក្បាលដី(ទួលអ្នកតា) នៅភូមិក្រសាំងផ្អែម
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ២២ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៩ គ្រួសារ នៅភូមិត្រពាំងលើក
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ២៥៥ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៥៨ គ្រួសារ នៅភូមិ
- អណ្ដូងច្រុះ ។

ខ.ឃុំមានជ័យមាន០២ភូមិរួមមាន ៖

- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន២០០ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៧៩ គ្រួសារ និងផ្ដល់សិទ្ធិជាកម្មសិទ្ធិសាធារណៈចំនួន ០១ ក្បាលដី (ត្រពាំងទឹក) នៅភូមិស្អុកស្អាត ។
- ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជនចំនួន ២២ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២១ គ្រួសារនៅភូមិស្អុក។

**មាត្រា ពីរ.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០១៣

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ពីរ*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com